# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

~~~~~~~~

# របាយការណ៍វឌ្ឍនភាព ត្រីមាសទី ១ ឆ្នាំ២០១០

### លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

របាយការណ៍វឌ្ឍនភាពត្រីមាសទី ១ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទី ២ នឹងធ្វើការបង្ហាញវឌ្ឍនភាពនៃការអនុវត្តការងារដែលមាននៅក្នុងខែមករា ខែកុម្ភៈ និងខែមីនា ឆ្នាំ ២០១០ ព្រមទាំងបញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះ ទន្ទឹមនេះសូចនាករសំខាន់ៗនៃភាពជឿទុកបាននៃថវិកា ក៏ត្រូវបានបន្តត្រួតពិនិត្យផងដែរ។

## ១. វឌ្ឍនភាពផ្អែកតាមសូចនាករក្នុងវិស័យគោលគន្លឹះនៃដំណាក់កាលទី ១/ជំហានទី ១

ភាពជឿទុកបាននៃថវិកា ត្រូវបានបន្តពិនិត្យតាមដាននៅក្នុងដំណាក់កាលទី២តាមរយៈការពិនិត្យបណ្តាសូចនាករដែលអាចវាស់វែងជាបរិមាណបាននៃជំហានទី១ ដែលមានបង្ហាញជូននៅក្នុងតារាងខាងក្រោមៈ

| សូចនាករ | គោលដៅ | វឌ្ឍនភាពត្រីមាសទី ១ ឆ្នាំ ២០១០ | វឌ្ឍនភាពត្រីមាសទី ១ ឆ្នាំ ២០០៩ |
|---|---|---|---|
| ១.លទ្ធផលចំណូលក្នុងស្រុកសរុបជាបណ្តើៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ | ចំណូលក្នុងស្រុកសរុបសម្រេចបាន + ឬ - ៥% ធៀបនឹងគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ | ចំណូលក្នុងស្រុកៈ ២២.៨ ٪ | ចំណូលក្នុងស្រុកៈ ២១.៤% |
| ២.គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២% នៃចំណាយសរុប | មិនមានបំណុលកកស្ទះ | មិនមានបំណុលកកស្ទះ |
| ៣.អាណាប័កជាបណ្តើៗអាចបញ្ជាចំណាយទៅតាមកម្មវិធីចំណាយនិងផែនការសាច់ប្រាក់ | ស្ថានភាពចំណាយមិនត្រូវតិចជាងៈ<br>- ត្រីមាសទី១ៈ ១៥%<br>- ត្រីមាសទី២ៈ ៤៥%<br>- ត្រីមាសទី៣ៈ ៦៧%<br>- ត្រីមាសទី៤ៈ ៩៦%<br>ភាគរយនៃការទូទាត់ជូនអ្នកផ្គត់ផ្គង់និងបុគ្គលិកតាមប្រព័ន្ធធនាគារមិនត្រូវតិចជាង៨០٪នៃ | សម្រេចបានក្នុងៈ<br><br>- ត្រីមាសទី១ៈ ១៦.៣ ٪<br><br>-ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន ៧៨.៩២ ٪<br>-ក្រសួង-ស្ថាប័នចំនួន៣៧ (លើកលែងក្រសួងការពារជាតិ) បានបើកបៀវត្សតាម | សម្រេចបានក្នុងៈ<br><br>-ត្រីមាសទី ១ៈ ១៧.៨%<br><br>-ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន ៨៥%<br>-នៅដំណាច់ឆ្នាំ២០០៩ក្រសួងចំនួន ២៦ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ |
~~~~~~~~

| | | | |
|---|---|---|---|
| | ចំណាយសរុប<br><br>ភាគរយនៃការបង់ចំណូលតាមរយៈប្រព័ន្ធធនាគារមិនត្រូវតិចជាង៦០%នៃចំណូលសរុប | ប្រព័ន្ធធនាគារ<br><br>-ចំណូលពន្ធគយ: ៨៩.៩ %<br>-ចំណូលពន្ធដារ: ៩៧.៥ % | <br><br>-ចំណូលពន្ធគយ:៩២%<br>-ចំណូលពន្ធដារ: ៩៦% |
| ៤.ចំណាយតាមប្រភេទ(សម្រាប់បុគ្គលិក និង មិនមែនបុគ្គលិក) កាន់តែខិតទៅរកថវិកាដែលបានអនុម័ត | លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង:<br><br>-បៀវត្ស: ៩៨%<br>-ទំនិញ/សេវាកម្ម: ៩៥%<br>-មូលធន: ៨៥% | សម្រេចបាន:<br><br>-បៀវត្ស: ១៧.៨%<br>-ទំនិញ/សេវា: ១៣.៨%<br>-មូលធន: ១៥.៤% | សម្រេចបាន:<br><br>-បៀវត្ស: ១៨.៨%<br>-ទំនិញ/សេវា: ១២.៩%<br>-មូលធន: ២០.៣% |
| ៥.ទិន្នផលចំណូលលើមូលដ្ឋានពន្ធកាន់តែប្រសើរជាងមុនតាមរយៈការកែលម្អប្រសិទ្ធភាពនៃការប្រមូល និង ផែនការប្រើប្រាស់ប្រភពចំណូលមិនមែនសារពើពន្ធ | ការរួមចំណែកទៅក្នុង ផសស នៃចំណូលសរុបមានការកែលម្អដោយបង្កើនប្រមាណ០.៥%ក្នុងមួយឆ្នាំ | -ចំណូលពន្ធ: ២០.៣%<br>.ពន្ធផ្ទាល់: ២១%<br>.ពន្ធប្រយោល: ២០.១%<br>-ចំណូលមិនមែនសារពើពន្ធ: ៣៧.៤% | -ចំណូលពន្ធ: ២២.១%<br>.ពន្ធផ្ទាល់: ២៩.១%<br>.ពន្ធប្រយោល:២០.៧%<br>-ចំណូលមិនមែនសារពើពន្ធ: ១៨.៥% |
| ៦.រាល់ផ្នែកសំខាន់ៗនៃចំណូល និងចំណាយសាធារណៈត្រូវបានដាក់បញ្ចូលក្នុងថវិកា និងគណនីរបស់រដ្ឋាភិបាល | មិនមានផ្នែកសំខាន់ៗដែលត្រូវបានដកចេញ | -បានបន្តពង្រឹងគណនីទោលរតនាគារ និងការប្រមូលផ្តុំគណនីរដ្ឋាភិបាល<br>-បន្តកែលម្អការអនុវត្តប្លង់គណនេយ្យថ្មី ចំណាត់ថ្នាក់ថវិកាថ្មី ចំណាត់ថ្នាក់ថវិកាថ្មី និងផែនការយុទ្ធសាស្ត្រថវិកា<br>-មកដល់ចុងខែមីនាឆ្នាំ២០១០ គណនីចរន្តទូទាំងប្រទេសបានថយចុះមកត្រឹមចំនួន ៨៧ | -បានបន្តពង្រឹងគណនីទោលរតនាគារ និងការប្រមូលផ្តុំគណនីរដ្ឋាភិបាល, ដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី, ចំណាត់ថ្នាក់ថវិកាថ្មី និងផែនការយុទ្ធសាស្ត្រថវិកាបានរួមចំណែកដល់ការកែលម្អ ការដាក់បញ្ចូលចំណូល និងចំណាយក្នុងគណនីរដ្ឋាភិបាល ណែនាំឱ្យមានការបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១០-២០១២នូវចំណូល<br>-ចំណាយរបស់សហគ្រាសពាណិជ្ជ និងឧស្សាហកម្មថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាក្រៅបរិបថរបស់ដៃគូអភិវឌ្ឍន៍<br>- នៅដំណាច់ឆ្នាំ ២០០៩ គណនីចរន្តទូទាំងប្រទេសបានថយចុះមកត្រឹមចំនួន ១១០គណនី<br>-ប្រព័ន្ធទិន្នន័យ(DMFAS) បានដំណើរការដើម្បីកែលម្អការគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញប្បទានពីខាងក្រៅ |

## ២. ការវាស់វែងសមិទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី២

ការត្រួតពិនិត្យមើលការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី២ បានផ្តោតលើវឌ្ឍនភាពនៃផែនការសកម្មភាពទាំងបីប្រភេទដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួម នោះគឺការពិនិត្យមើលវឌ្ឍនភាពសកម្មភាពជំហានទី១ដែលត្រូវបន្តពង្រឹងក្នុងដំណាក់កាលទី២, វឌ្ឍន-ភាពសកម្មភាពដើម្បីសម្រេចគោលបំណងផ្ទាល់នៃជំហានទី ២ និងវឌ្ឍនភាពសកម្មភាពសម្រាប់ជំហានបន្ទាប់។

## ២.១ សកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី២

ការពិនិត្យមើលវឌ្ឍនភាពនៃសកម្មភាពទាំងនេះ ដែលរៀបចំក្រោមគោលបំណងចំនួនបួន គឺដើម្បីធានាថាភាពជឿទុកចិត្តបាននៃថវិកាដែលជាសមិទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ដំណាក់កាលទី១ នៅតែរក្សាបាន ដើម្បីគាំទ្រដល់ការសម្រេចគោលបំណងនៃកំណែទម្រង់ជំហានទី ២ "**ការធ្វើឱ្យប្រសើរឡើងគណនេយ្យភាពហិរញ្ញវត្ថុ**" ។

### . បន្តកែលម្អរដ្ឋបាល និង គោលនយោបាយចំណូល

### *ផ្នែកចំណូលមិនមែនសារពើពន្ធ*

ក្នុងផ្នែកនេះ សកម្មភាពដែលបានអនុវត្តរួមមានដូចជា: ការរៀបចំសេចក្តីព្រាងនីតិវិធីចុះត្រួតពិនិត្យអនុបំណុលរបស់រដ្ឋាភិបាលនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ សេចក្តីព្រាងតារាងកម្រៃជើងសារសម្រាប់ក្រុមហ៊ុនប្រកបសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ សេចក្តីព្រាងស្តង់ដាគ្រប់គ្រងសេវាកម្មអចលនវត្ថុ ការដាក់អនុវត្តប្រកាសស្តីពីការគ្រប់គ្រងអចលនវត្ថុ (ប្រកាសចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០៩) បានរៀបចំពាក្យស្នើសុំអាជ្ញាប័ណ្ណ និងសៀវភៅបន្ទុកសម្រាប់បុគ្គលអភិវឌ្ឍន៍អលនវត្ថុ បានចេញប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណសម្រាប់ក្រុមហ៊ុនវិស្វកម្មឯករាជ្យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ អនុក្រឹត្យស្តីពីការបោះផ្សាយ និងការជួញដូរមូលប័ត្រមហាជន និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលប័ត្រកម្ពុជា បន្តការពិភាក្សាជាមួយក្រសួង-ស្ថាប័នអំពីសេចក្តីព្រាងប្រកាសអន្តរក្រសួងដើម្បីពង្រឹង និងគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ ពិភាក្សាបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និង

កែលម្អខ្លឹមសារសារាចរស្តីពីការដាក់ឱ្យអនុវត្តបង្កាន់ដៃជាតិ ឱ្យមានសង្គតិភាពទៅនឹងបទប្បញ្ញត្តិដែលមានជាធរមាន បានកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ការលើកទឹកចិត្តដល់មន្ត្រីអនុវត្តការប្រមូលចំណូល និងរង់ចាំការផ្តល់អនុសាសន៍ពីថ្នាក់ដឹកនាំ បន្តការពិនិត្យស្ថានភាពបំណុលពីការធ្វើឯកជនភាវូបនីយកម្ម រៀបចំវិធានការទាមទារការទូរទាត់បំណុលដែលបុគ្គលឯកជនជំពាក់រដ្ឋ បន្តសិក្សាប្រភពចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រៀបចំចងក្រងឯកសារច្បាប់ និងបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបន្តរៀបចំសារាចរណែនាំស្តីពីការពង្រឹងអនុវត្តមាត្រា ១៧ នៃច្បាប់ស្តីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

### ផ្នែកចំណូលសារពើពន្ធ

សកម្មភាពដែលបានអនុវត្តរួចរួមមានៈការអនុវត្តវិធានការតឹងទារចំពោះសហគ្រាសជំពាក់បំណុលពន្ធ និងពិនិត្យសហគ្រាសជំពាក់បំណុលនៅសាខាពន្ធដារខណ្ឌទាំង ០៧ រៀបចំផែនការជំរឿនសហគ្រាសនៅភ្នំពេញ កែសម្រួលសេចក្តីណែនាំអំពីសិទ្ធិ និងកាតព្វកិច្ចអ្នកជាប់ពន្ធ រៀបចំសិក្ខាសាលាពង្រឹងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅសាខាពន្ធដារខណ្ឌទាំង ០៧ បន្តការងារចងក្រង និងបញ្ចូលទិន្នន័យរួមក្នុងអគ្គនាយកដ្ឋានពន្ធដារ កម្មវិធីសវនកម្មផ្នែកពន្ធដារកំពុងសិក្សាបន្ត ការរៀបចំគោលការណ៍គ្រប់គ្រង និងតាមដានការកៀរគរចំណូលពីប្រេងឧស្ម័ន និងធនធាន គំរូសេដ្ឋកិច្ចដើម្បីវិភាគព្យាករណ៍ចំណូលរបស់ក្រុមហ៊ុន និងរដ្ឋទទួលបាន សេចក្តីព្រាងលើកទី៣ស្តីពីបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការប្រេងត្រូវបានកែសម្រួល ដោយមានការផ្តល់យោបល់ពីអាជ្ញាធរជាតិប្រេងកាត អង្គការរូបិយវត្ថុអន្តរជាតិ និងក្រុមហ៊ុន Cheveron បានបង្កើតអនុក្រុមការងារគ្រប់គ្រងចំណូលពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែ គោលនយោបាយចំណូលត្រូវបានធ្វើបច្ចុប្បន្នភាព និងកែលម្អ ដោយមានការផ្តល់ជំនួយបច្ចេកទេសពីទីប្រឹក្សាបរទេស ព្រមជាមួយការធ្វើបច្ចុប្បន្នភាពម៉ាក្រូសេដ្ឋកិច្ច និងបានធ្វើការសិក្សាពីផលប៉ះពាល់នៃការកាត់បន្ថយពន្ធនាំចូលក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់អាស៊ានលើចំណូល។

ក្រសួង-ស្ថាប័នក៏បានរួមចំណែកក្នុងការធ្វើការរបាយការណ៍គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌចលន និងអចលនទ្រព្យ ផ្តល់ព័ត៌មានអំពីប្រភពចំណូល ជំរុញ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល ការទារបំណុល ពង្រឹងប្រព័ន្ធកត់ត្រាចំណូលនិងផ្សព្វផ្សាយអំពីនីតិវិធីប្រមូលចំណូល។

- **បន្តកែលម្អការគ្រប់គ្រងបំណុល**

ប្រព័ន្ធ **DMFAS** កំពុងត្រូវបានពិនិត្យកែលម្អដោយសហការជាមួយទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិ ព្រមទាំងធ្វើសមាហរណកម្មមុខងារវិភាគចីរភាពបំណុល **(DSA)** នៅក្នុងការិយាល័យគ្រប់គ្រងបំណុល និងបានជ្រើសរើសអ្នកជំនាញការជាតិ ០១រូបទទួលបន្ទុក។ សិក្ខាសាលាស្តីពីការវិភាគចីរភាពបំណុលត្រូវបានរៀបចំឡើងដោយសហការជាមួយទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី **(ADB)** ។

- **បន្តកែលម្អការគ្រប់គ្រងសាច់ប្រាក់ និង ការគ្រប់គ្រងគណនីធនាគារ**

នៅដើមឆ្នាំ ២០១០ គណនីចរន្តទូទាំងប្រទេសមានចំនួន ៩០ គណនី ហើយត្រូវកាត់បន្ថយនៅសល់ត្រឹម ៨៧ គណនី គិតត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១០ ។ នៅថ្នាក់កណ្តាលពុំមានគណនីដែលត្រូវបន្តតាមដានទេ គណនីដែលនៅសល់ចំនួន ១០ ជាគណនីមានការអនុញ្ញាត។ គណនីរបស់ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករត្រូវបានរក្សាសមតុល្យសូន្យនៅរៀងរាល់ចុងថ្ងៃ។ ការគ្រប់គ្រងគណនីត្រូវបានអនុវត្តជាបន្តដោយសហការជាមួយអង្គភាពពាក់ព័ន្ធ។ គិតត្រឹមខែកញ្ញា ឆ្នាំ២០០៩ ក្រសួង-ស្ថាប័នប្រើប្រាស់សេវាធនាគារដើម្បីបើកប្រាក់បៀវត្សមានចំនួន២៦ ហើយបានកើនឡើងដល់ ៣៧ នៅដើមឆ្នាំ២០១០ (លើកលែងក្រសួងការពារជាតិ)។ គម្រោងពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល-ចំណាយ ដែលត្រូវអនុវត្តសាកល្បងក្នុងខេត្តចំនួន០៧ បន្ថែម (ឆ្នាំ២០០៩ មានចំនួនត្រឹម ០២) កំពុងធ្វើការសិក្សា និងរៀបចំដោយសហការជាមួយទីប្រឹក្សាបរទេស និងបានប្រជុំពិភាក្សាលើសេចក្តីព្រាងឯកសារដេញថ្លៃក្នុងក្របខ័ណ្ឌគណៈកម្មការចម្រុះរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា។ គំរូរបាយការណ៍សាច់ប្រាក់រដ្ឋត្រូវបានបន្តរៀបចំ និងតារាងចំណូល-ចំណាយរបស់ក្រសួង-ស្ថាប័នក៏ត្រូវបានធ្វើបច្ចុប្បន្នភាពផងដែរ។ផ្អែកតាមលទ្ធផល

របាយការណ៍ជាទៀងទាត់អំពីស្ថានភាពប្រតិបត្តិការចំណូល-ចំណាយនិងការត្រួតពិនិត្យអាយុកាលអាណត្តិ បំណុលកកស្ទះនៅអគ្គនាយកដ្ឋានរតនាគារជាតិមិនមានឡើយ។

- **បន្តកែលម្អលទ្ធកម្មសាធារណៈ**

សេចក្តីព្រាងគោលនៃច្បាប់លទ្ធកម្មសាធារណៈ ត្រូវបានដាក់ពិនិត្យ ពិភាក្សានៅក្នុងក្របខ័ណ្ឌនាយកដ្ឋាន ឯកសារស្តង់ដារដេញថ្លៃត្រូវបានធ្វើការកែលម្អជាបន្ត ឯកសារសារាចរណែនាំបន្ថែមស្តីពីការកសាងផែនការលទ្ធកម្មប្រចាំឆ្នាំ ២០១០ ត្រូវបានរៀបចំឡើង និងបានធ្វើការផ្សព្វផ្សាយដល់ក្រសួង-ស្ថាប័នចំណាយ។ ទន្ទឹមនេះ សកម្មភាពមួយចំនួនទៀតក៏ត្រូវបានអនុវត្តផងដែររួមមានៈ ការរៀបចំចងក្រង និងបោះពុម្ពសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងលទ្ធកម្មសាធារណៈ ធ្វើការត្រួតពិនិត្យឡើងវិញលើបរិបទការងារនៃកិច្ចលទ្ធកម្មរបស់ក្រសួង-ស្ថាប័នមួយចំនួន ការរៀបចំប្រកាសស្តីពីការគ្រប់គ្រងលទ្ធកម្មរាជធានី-ខេត្តឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញលទ្ធកម្មដល់ក្រសួង-ស្ថាប័នចំណាយ ការជ្រើសរើសជំនាញការបរទេសសម្រាប់សវនកម្មជាក្រោយ ការបន្តការងាររៀបចំគេហទំព័រសម្រាប់លទ្ធកម្មសាធារណៈ និងបានរៀបចំគំរូសំណួរសម្រាប់សម្រង់ទិន្នន័យនៃដំណាក់កាលលទ្ធកម្មរបស់ក្រសួង-ស្ថាប័នចំណាយ។

## ២.២ សកម្មភាពជំហានទី ២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី២

នៅក្នុងដំណើរការឆ្ពោះទៅរកការសម្រេចឱ្យបាននូវការធ្វើឱ្យប្រសើរឡើងគណនេយ្យភាពហិរញ្ញវត្ថុ ដែលជាគោលបំណងចំបងជាយុទ្ធសាស្ត្រនៃជំហានទី ២ នោះ ចង្កោមសកម្មភាពការងារ ត្រូវបានចងក្រងនៅជុំវិញវិញគោលបំណងចំនួន០៨ដែលជោគជ័យក្នុងគោលបំណងទាំងអស់នេះ នឹងនាំឱ្យគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានកែលម្អប្រសើរឡើង។

- **កែលម្អបន្ទាត់គណនេយ្យភាពដោយកំណត់ឱ្យបានច្បាស់ពីតួនាទី មុខងារ និង ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន គ្រប់កម្រិត និងរបស់អង្គភាពក្រោមឱវាទ**

ដំណើរការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានកំពុងអនុវត្តបន្ត ការងារប្រមូលចងក្រងរចនាសម្ព័ន្ធក្រសួង-ស្ថាប័នស្ទើរតែបញ្ចប់ទាំងស្រុង (លើកលែងក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង

ទីស្តីការគណៈរដ្ឋមន្ត្រី) ហើយក៏បន្តការពិនិត្យ ពិភាក្សា ក្នុងក្របខ័ណ្ឌផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងក្របខ័ណ្ឌអង្គភាពថវិកាដែលរៀបចំដោយទីប្រឹក្សាបរទេសផងដែរ។ ក្រសួង-ស្ថាប័នបានរួមចំណែកលើការងាររៀបចំគំនូសបំព្រួញលំហូរថវិកា និងគណនេយ្យភាព ការពិនិត្យអំពីការរៀបចំអង្គភាព និងអ្នកគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកា គណនេយ្យភាពថ្មី ។ ក្នុងក្របខ័ណ្ឌនៃការងារផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ ដំណើរការចាត់បញ្ជូនក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅអមក្រសួង-ស្ថាប័នចំនួន ១១បានអនុវត្តរួចរាល់។

- **កែលម្អឧបករណ៍ដែលជំរុញឱ្យមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុនិងការពង្រឹងគណនេយ្យភាព**

មាតិកានៃគោលការណ៍ណែនាំស្តីពីនីតិវិធី និងបរិបថនៃការធានាចំណាយ និងការទូទាត់អាណត្តិបើកប្រាក់ត្រូវបានរៀបចំ និងគ្រោងរៀបចំសរសេរលម្អិតតាមចំណុចនីមួយៗ ព្រមជាមួយនេះ សិក្ខាសាលាស្តីពីស្តង់ដារអធិការកិច្ចហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយមានជំនួយបច្ចេកទេសពីប្រទេសបារាំង។

- **បន្តកែលម្អការអនុវត្តមាតិកាថវិកាថ្មី និង ប្លង់គណនេយ្យថ្មី**

សេចក្តីពន្យល់អំពីចំណាត់ថ្នាក់សេដ្ឋកិច្ចត្រូវបានរៀបចំកែលម្អជាបណ្តើរៗនិងបន្តពិនិត្យពិភាក្សាលើសេចក្តីព្រាងរៀបចំអនុ-អនុគណនី។ ដំណើរការរៀបចំចំណាត់ថ្នាក់ថវិកាតាមចំណាត់ទាំង០៦ (រដ្ឋបាល ភូមិសាស្ត្រ សេដ្ឋកិច្ច មុខងារ កម្មវិធី និងប្រភពធនធាន) ត្រូវបានរៀបចំបង្ហាញដល់មន្ត្រីពាក់ព័ន្ធ(នាយកដ្ឋានថវិកា) និងបានពិនិត្យវាយតម្លៃលើការរៀបចំចំណាត់ថ្នាក់មុខងារដោយផ្អែកតាមឯកសារចំណាត់ថ្នាក់មុខងាររបស់រដ្ឋាភិបាល COFOG ។ បន្ថែមលើនេះសកម្មភាពពាក់ព័ន្ធមួយចំនួន មានដូចជា: ធ្វើការសិក្សាអំពីការបង្កើតលេខកូដសម្រាប់សំគាល់កម្មវិធី ការចូលរួមសិក្ខាសាលាស្តីអំពី Government Financial Statistics 2001 រយៈពេល ០៥ ថ្ងៃនៅប្រទេសសិង្ហបុរី មន្ត្រីអនុវត្តការងារបានទទួលការបង្ហាត់បង្ហាញអំពីចំណាត់ថ្នាក់តាមកម្មវិធី និងចំណាត់ថ្នាក់មុខងារពីជំនាញការអង្គការរូបិយវត្ថុអន្តរជាតិ ដំណើរការចងក្រង និងផ្សព្វផ្សាយឯកសារដែលពាក់ព័ន្ធនឹងការងាររតនាគារជាតិបានប្រព្រឹត្តទៅស្ទើរតែចប់ទាំងស្រុង ព្រមទាំងបានធ្វើការពិនិត្យដោះស្រាយបញ្ហាថវិកានៅឃុំ សង្កាត់ បន្តកែលម្អមាតិកាគណនីនៅក្នុងតារាង TOFE និងធ្វើការកែសម្រួលការតភ្ជាប់មាតិកាគណនីថ្មីទៅក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) និងធ្វើ

បច្ចុប្បន្នភាព TOFE ២០០៨, TOFE ខែមករា-ធ្នូ ២០០៩ និង GFS ខែមករា-ធ្នូ ២០០៩ បានប្រជុំពិភាក្សាជាមួយជំនាញការបរទេសលើការងារចំណាត់ថ្នាក់ថវិកា ការងារគណនេយ្យ ការគ្រប់គ្រងសាច់ប្រាក់ និងអភិក្រមការងារ។

## - កែលម្អដំណើរការ និងប្រតិបត្តិការអនុវត្តថវិកា

ក្នុងក្របខ័ណ្ឌនៃការកែលម្អដំណើរការ និងប្រតិបត្តិការអនុវត្តថវិកា សកម្មភាពមួយចំនួនត្រូវបានប្រកាន់យកដែលមាន ការបញ្ឈប់ចំណាយលើសលទ្ធភាពថវិកា ការកាត់បន្ថយឥណទានជាប់សន្យាដែលជាបំណុលកកស្ទះជាបណ្តើរៗ បានកំពុងរៀបចំសេចក្តីព្រាងលម្អិតបទប្បញ្ញត្តិអនុវត្តអនុក្រឹត្យស្តីពីការកែលម្អនីតិវិធីចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសម្រាប់ថវិកាបុរេប្រទាន បានធ្វើការត្រួតពិនិត្យកិច្ចបញ្ជីកាគណនេយ្យ រដ្ឋទេយ្យបុរេប្រទាននៅតាមក្រសួង-ស្ថាប័ន កំពុងសិក្សាអំពីនីតិវិធីដែលត្រូវធ្វើសមាហរណកម្មចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស និងក្រៅប្រទេស រៀបចំរបាយការណ៍ចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសឆ្នាំ២០០៩ រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ប្រាក់បេសកកម្មក្នុង និងក្រៅប្រទេស សេចក្តីព្រាងសារាចរណែនាំស្តីពីការប្រើប្រាស់ និងការផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ធ្វើការពិនិត្យ ពិភាក្សាការដាក់លេខកូដចំណាត់ថ្នាក់ថវិកា និងរៀបចំសេចក្តីព្រាងនៃការបង្កើតអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ច បានរៀបចំកំណត់ប្លង់គណនេយ្យសម្រាប់គម្រោងFMIS កំពុងរៀបចំឯកសារពាក់ព័ន្ធនឹងការបើកការដេញថ្លៃប្រព័ន្ធ FMIS នាពេលខាងមុខ ធ្វើការប្រជុំតំបូងជាមួយក្រុមហ៊ុនទាំងបួនដែលនឹងចូលដេញថ្លៃប្រព័ន្ធ FMIS ដើម្បីឆ្លើយសំណួរ និងបង្ហាញលក្ខន្តិកៈក្នុងការដេញថ្លៃ និងបានបង្ហាញគំរូ Business Process ឱ្យក្រុមហ៊ុនទាំងបួន កំពុងរៀបចំបញ្ចប់ការកំណត់នូវនីតិវិធីអនុវត្តការងារដ៏ប្រសើរមួយដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ សម្រេច បានរៀបចំប្រជុំពិភាក្សាជាមួយក្រុមហ៊ុនឯកជនលើដំណើរការអភិវឌ្ឍកម្មវិធីគណនេយ្យនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងធ្វើការបណ្តុះបណ្តាលមូលដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យាដល់មន្ត្រីរតនគារនៅខេត្តចំនួន ០២។

- **កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីធានាតម្លាភាព**

សកម្មភាពដែលបានអនុវត្តក្នុងផ្នែកនេះមានដូចជា ការពិនិត្យឡើងវិញនូវស្តង់ដារគណនេយ្យសាធារណៈ និងការរៀបចំអនុវត្តឱ្យស្របជាមួយការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ការកែសម្រួលប្រកាសស្តីពីនីតិវិធីបណ្តឹងតវ៉ាផ្នែកពន្ធដារ និងបន្តរៀបចំសៀវភៅណែនាំស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ការងាររៀបចំតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ TOFE ដាក់ចូលគេហទំព័រកំពុងបន្តអនុវត្ត ។

ក្រសួង-ស្ថាប័ន បានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការរៀបចំបញ្ជីសារពើភ័ណ្ឌ ការចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុ ផ្តល់មតិយោបល់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ រៀបចំ និងអនុវត្តតាមគំរូរបាយការណ៍អនុវត្តថវិកាផ្ទៃក្នុង។

- **កែលម្អសវនកម្ម និងអធិការកិច្ច ព្រមទាំងឆ្លើយតបទៅនឹងការប្រើប្រាស់លទ្ធផលនៃរបាយការណ៍សវនកម្ម និង អធិការកិច្ច**

ផែនការការងារអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ ២០១០ និងផែនការរយៈពេល ០៣ឆ្នាំ (២០១០-២០១២)បាន និងកំពុងរៀបចំកែលម្អព្រមជាមួយនេះរបាយការណ៍លទ្ធផលអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ២០០៩ ក៏ត្រូវបានរៀបចំផងដែរ។ ជាទូទៅ ក្រៅពីគណៈកម្មការមូលប័ត្រដែលបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ចំនួនអង្គភាពសវនកម្មផ្ទៃក្នុងនៅតាមក្រសួង មិនមានការប្រែប្រួលឡើយ (ឆ្នាំ២០០៩ ក្រសួង១៨ ក្នុងចំណោម ២៦ដែលបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានដំណើរការ និងសហគ្រាសសាធារណៈចំនួន ០៣)។ ការងារសវនកម្មលើអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានអនុវត្តជាបន្តបន្ទាប់ ។ ការរៀបចំសៀវភៅណែនាំនីតិវិធីសវនកម្មទូទៅ ការងាររៀបចំយុទ្ធសាស្ត្រសវនកម្ម (០៣ឆ្នាំ)តាមនីតិវិធីថ្មី កំពុងដំណើរការ ។ ទន្ទឹមនេះ បទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំចងក្រងនិងធ្វើការផ្សព្វផ្សាយដល់អង្គភាពសវនកម្មនៃក្រសួង-ស្ថាប័ន ប្រអប់សំបុត្រសវនកម្មត្រូវបានធ្វើការផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន ហើយនាយកដ្ឋានសវនកម្មផ្ទៃក្នុងក៏បានចូលរួមចំណែកពិនិត្យកែសម្រួលផែនការសវនកម្មប្រចាំឆ្នាំ២០១០ និងផែនការបីឆ្នាំរំកិលរបស់ក្រសួងចំនួន០៤។

ការងាររៀបចំសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន កំពុងមានដំណើរការជាបណ្តើរៗ ដោយបានសហការជាមួយនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អាជ្ញាធរសវនកម្មជាតិ ដោយបានបណ្តុះបណ្តាលមន្ត្រីជំនាញទទួលបន្ទុក ការរៀបចំនីតិវិធី ផែនការនិងរបាយការណ៍សវនកម្ម ការបង្កើតប្រអប់សំបុត្រសវនកម្មនៅតាមរាជធានី-ខេត្ត ការបង្កើតប្រព័ន្ធទិន្នន័យសម្រាប់ត្រួតពិនិត្យផ្ទៃក្នុង ការរៀបចំបញ្ជីសំណួរសវនកម្ម ។

**- ពង្រឹង និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ**

ការពង្រឹង និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ ត្រូវបានអនុវត្តជាបន្ត ដូចជាការពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំសេចក្តីព្រាងបែងចែកចំណូលទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំ និងកែលម្អយុទ្ធសាស្ត្ររយៈពេលខ្លីសម្រាប់ការអនុវត្តវិមជ្ឈការហិរញ្ញវត្ថុ (២០០៩-២០១១) និងយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការអនុវត្តវិមជ្ឈការហិរញ្ញវត្ថុ(២០១១-២០១៨)។

**- ការកសាងសមត្ថភាពស្ថាប័ន និងវិធានការលើកទឹកចិត្ត**

សកម្មភាពពាក់ព័ន្ធនឹងការកសាងសមត្ថភាព និងស្ថាប័នជាច្រើនត្រូវបានអនុវត្តដោយតួអង្គពាក់ព័ន្ធ ដែលក្នុងនោះអាចរាប់បញ្ចូល ការវិភាគវាយតម្លៃលើតម្រូវការសម្រាប់ការបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នទាំងអស់ ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព និងបន្តរៀបចំផែនការសកម្មភាពសម្រាប់ការបណ្តុះបណ្តាលនៅក្នុងដំណាក់កាលទី ២ នៃកម្មវិធីកែទម្រង់ បានបញ្ចប់ឯកសារគម្រោងកម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍជំនាញឯកទេសហើយបានដាក់ជូនធនាគារពិភពលោកដើម្បីពិនិត្យ និងសម្រេចផ្តល់ការគាំទ្រផ្នែកថវិកា កំពុងដំណើរការរៀបចំកម្មវិធីបណ្តុះបណ្តាលដោយសហការជាមួយ Civil Service College របស់ប្រទេសសិង្ហបុរី (Twinning Program) បានរៀបចំដំឡើង Server សម្រាប់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា(HRMIS) នៅនាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ កំពុងរៀបចំ Software សម្រាប់ HRMIS ចាប់ផ្តើមដំណើរការដេញថ្លៃបោះពុម្ពកម្រងឯកសារច្បាប់ និងវិធានគ្រប់គ្រងធនធានមនុស្ស និង រចនាសម្ព័ន្ធគ្រប់គ្រង និងរដ្ឋបាលរបស់ក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំពុងសិក្សាអំពីនីតិវិធី និងលក្ខខណ្ឌសម្រាប់ការរៀបចំប្រឡងផ្ទៃក្នុងប្តូរក្របខ័ណ្ឌមន្ត្រីរាជការដើម្បីជាការលើកទឹកចិត្តដល់មន្ត្រីរាជការ បានបញ្ចប់បេសកកម្មប្រមូលទិន្នន័យមន្ត្រីរាជរាជការនៅទីស្តីការក្រសួង និងអគ្គនាយកដ្ឋាន ព្រមទាំងបានរៀបចំនីតិវិធី និងឯកសារពាក់ព័ន្ធ ដើម្បីគាំទ្រដល់ដំណើរការជំរឿនមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាពេលខាងមុខ ព្រមជាមួយនេះ គោលការណ៍ណែនាំអំពីវិធានការគ្រប់គ្រងក្របខ័ណ្ឌ និងវត្តមានមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានអនុម័ត និងត្រៀមដាក់ឱ្យដំណើរការ។ គោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ឯកសារណែនាំអំពីនីតិវិធីគ្រប់គ្រងមន្ត្រីរាជការ ក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លក្ខខណ្ឌការងារជ្រើសរើសទីប្រឹក្សាបរទេសផ្នែកការងារវិភាគមុខងារ និងស្ថាប័ន ត្រូវបានរៀបចំ និងដាក់ឱ្យមានការពិនិត្យ ពិភាក្សា នៅក្នុងក្របខ័ណ្ឌនាយកដ្ឋាន។ ដោយឡែក សេចក្តីព្រាងលក្ខន្តិកៈសមាគមសង្គហមិត្តបុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានពិនិត្យបញ្ចប់ និងត្រៀមដាក់ជូនថ្នាក់ដឹកនាំពិនិត្យ សម្រេច។ ដំណើរការសិក្សា និងពិភាក្សាអំពីលទ្ធភាពនៃផ្តល់ការឧបត្ថម្ភចំពោះចំណាយប្រតិបត្តិការជាអាទិភាព (POC) សម្រាប់ការអនុវត្តគម្រោង កំពុងមានដំណើរការទៅមុខ។

បន្ថែមលើសកម្មភាពដែលបានរៀបរាប់នៅខាងលើនេះ វគ្គសិក្សា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាមួយចំនួនត្រូវបានអនុវត្ត ក្នុងនោះមានមន្ត្រី ០១រូបបានចូលរួមវគ្គសិក្សាសម្រាប់អ្នកដឹកនាំវ័យក្មេងនៅប្រទេសជប៉ុន និង០២រូបបំពេញទស្សនកិច្ចសិក្សានៅសិង្ហបុរី និងគ្រោងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ភាពជាអ្នកដឹកនាំសម្រាប់ការគ្រប់គ្រងគោលនយោបាយសាធារណៈ" ចំនួន ២ វគ្គ (សិក្ខាកាម ៨៨នាក់) ផ្តល់ការបណ្តុះបណ្តាលរយៈពេលខ្លីចំនួន ២៤ថ្នាក់ដល់មន្ត្រីរាជការពីក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (វគ្គស្តីពីផែនការយុទ្ធសាស្ត្រផ្សារភ្ជាប់ថវិកា ប្រតិភូកម្មថវិកា ចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យ វិភាគថវិកា ផែនការ និងកម្មវិធីសវនកម្ម ការគ្រប់គ្រងគោលនយោបាយសាធារណៈសម្រាប់ភាពជាអ្នកដឹកនាំនិងផ្នែកព័ត៌មានវិទ្យា) មន្ត្រីគយចំនួន ១០០រូបបានចូល រួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងប្រទេស និងមន្ត្រីគយចំនួន ២៤រូបចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្រៅប្រទេស

បានរៀបចំផែនការបណ្តុះបណ្តាលជំហានទី ២(ក្នុង និងក្រៅប្រទេស) ក្រោមជំនួយរបស់ JICA សម្រាប់អគ្គនាយកដ្ឋានពន្ធដារ រៀបចំវគ្គបណ្តុះបណ្តាលប្រព័ន្ធព័ត៌មានវិទ្យានៅខេត្តចំនួន០៦ (អគ្គនាយកដ្ឋានពន្ធដារ) បានរៀបចំទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រង និងអនុវត្តគម្រោង FMIS នៅប្រទេស Uganda រៀបចំលក្ខខណ្ឌការងារ និងចាប់ផ្តើមធ្វើការជ្រើសរើសមន្ត្រី ០៥រូប ដើម្បីទទួលការបណ្តុះបណ្តាល និងជួយគាំទ្រដល់គម្រោង FMIS បានរៀបចំផែនការវគ្គបណ្តុះបណ្តាលសម្រាប់ពង្រឹងសមត្ថភាព FMIS ឆ្នាំ ២០១០ និងផែនការផ្តត់ផ្គង់សម្ភារះគាំទ្រសមត្ថភាពមន្ត្រីអនុវត្តគម្រោង FMIS និស្សិត០៤រូបក្រោមអាហារូបករណ៍នៃកម្មវិធីកំណែទម្រង់បានបញ្ចប់ការសិក្សាដោយជោគជ័យ និងត្រូវបានចាត់ឱ្យបំពេញការងារគាំទ្រដល់លេខាធិការដ្ឋានកំណែទម្រង់និងអគ្គនាយកដ្ឋាន/នាយកដ្ឋាន។

ក្រសួង-ស្ថាប័ន បានចូលរួមក្នុងការវាយតម្លៃអំពីតម្រូវការនៃការកសាងសមត្ថភាពដើម្បីឆ្លើយតបនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទន្ទឹមនេះក៏បានរៀបចំឱ្យមានកម្មវិធីផ្សព្វផ្សាយអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៅក្នុងក្រសួង-ស្ថាប័ន ។

### ២.៣ សកម្មភាពសម្រាប់ជំហានបន្ទាប់ដែលត្រូវចាប់ផ្តើមជាបណ្តើរៗ

វឌ្ឍនភាពនៃសកម្មភាពជំហានបន្ទាប់ គឺមានគោលបំណងកែលម្អ និងពង្រីកការអនុវត្តថវិកាតាមកម្មវិធី ព្រមទាំងកែលម្អភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មនៃថវិកា។

**.ការកែលម្អ និងការពង្រីកការអនុវត្តថវិកាតាមកម្មវិធី**

ក្រុមការងារជំនាញបានបន្តប្រជុំពិភាក្សាគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី និងធ្វើការផ្សព្វផ្សាយទៅក្រសួងសាកល្បងទាំង០៨ ធ្វើការពិនិត្យរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ដែលអនុវត្តថវិកាកម្មវិធី និងបានកំពុងរៀបចំផែនការការងារដើម្បីពង្រឹងការអនុវត្តសាកល្បងឡើងវិញក្រោមជំនួយបច្ចេកទេសពីទីប្រឹក្សាបរទេស ។ ទន្ទឹមនេះ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តទាំង ២៤ បានបន្តសាកល្បងថវិកាកម្មវិធីក្រោមការពិនិត្យតាមដានរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួង-ស្ថាប័នក៏បានធ្វើការកែលម្អផែនការយុទ្ធសាស្ត្ររបស់ខ្លួនដោយ

កំណត់នូវយុទ្ធសាស្ត្រក្នុងការសាកល្បង កសាងនិងអនុវត្តថវិកាកម្មវិធី រៀបចំផែនការប្រតិបត្តិការប្រចាំឆ្នាំ និងផែនការបីឆ្នាំរំកិល។

## ៃ បន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និង ការធ្វើសមាហរណកម្មថវិកា

សេចក្តីណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានពិនិត្យកែលម្អ ព្រមទាំងបានរៀបចំបទបង្ហាញដល់មន្ត្រីក្នុងក្របខ័ណ្ឌនាយកដ្ឋានថវិកា បានរៀបចំរួចរាល់នីតិវិធីនៃការដាក់ពិន្ទុនិងវាយតម្លៃ បានពិនិត្យ និងផ្ទៀងផ្ទាត់កម្មវិធីវិនិយោគសាធារណៈ(PIP)ជាមួយផែនការយុទ្ធសាស្ត្រថវិកា (BSP) ឆ្នាំ ២០១០-២០១២ របស់ក្រសួង-ស្ថាប័ន មន្ទីរជំនាញ ដើម្បីបូកសរុបប្រភពចំណូល-ចំណាយរបស់ដៃគូអភិវឌ្ឍន៍ រៀបចំសេចក្តីព្រាងគំរូរបាយការណ៍ចំណូល-ចំណាយដែលអនុវត្តក្រៅបរិបថថវិកា។ យន្តការប្រមូលព័ត៌មានពីក្រសួង-ស្ថាប័នស្តីពីខ្ទង់ចំណូល-ចំណាយក្រៅបរិបថថវិកា ត្រូវបានធ្វើការពិនិត្យ ពិភាក្សាជាបន្ត។ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ២០១១-២០១៣ ក៏ត្រូវបានធ្វើបច្ចុប្បន្នភាពផងដែរ។

ក្រសួង-ស្ថាប័ន ក៏បានខិតខំបង្កើនសមត្ថភាព និងជំរុញដំណើរការក្រុមការងារថវិការបស់ខ្លួនដើម្បីពង្រឹងប្រសិទ្ធភាពការរៀបចំកសាងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំនិងការធ្វើសមាហ-រណកម្មថវិកា។

## ៣ៃ បញ្ហាប្រឈម

បញ្ហាប្រឈមមួយចំនួន ត្រូវបានលើកបង្ហាញដោយអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ដែលអនុវត្តសកម្មភាពកំណែទម្រង់ ក្នុងនោះរួមមានៈ

- ធនធានមនុស្សដើម្បីបំពេញការងារនៅមានកម្រិត ទាំងបរិមាណនិងជំនាញបច្ចេកទេស។
- ផែនការបណ្តុះបណ្តាលមួយចំនួន នៅជាប់គាំងដោយរង់ចាំការសម្រេចគាំទ្រពីដៃគូកង្វះថវិកា ពុំមានគ្រូឧទ្ទេស និងសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ ។
- ការផ្តល់ការលើកទឹកចិត្តមិនគ្រប់គ្រាន់ ទន្ទឹមនេះគោលការណ៍ផ្តល់ការលើកទឹកចិត្តចំពោះមន្ត្រីប្រមូលចំណូលនៅមិនទាន់មានការសម្រេចនៅឡើយ។

- កង្វះជំនួយបច្ចេកទេសក្នុងវិស័យការងារមួយចំនួនដូចជា ផ្នែកអាជីវកម្មប្រេង ឧស្ម័ន ការគ្រប់គ្រងអាជីវកម្មផ្នែកកាស៊ីណូ ឆ្នោត ឡូតូ ការអនុវត្តមាតិកាថវិកាថ្មី និងគណនេយ្យថ្មី ការងារសវនកម្ម លទ្ធកម្មសាធារណៈ ជាដើម។
- កិច្ចសហការពីក្រសួង-ស្ថាប័ននៅមានកម្រិតនៅឡើយដូចជាផ្នែកគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការបង្កើតក្រុមការងារថវិកា ការទទួលព័ត៌មានអំពីមូលនិធិដៃគូអភិវឌ្ឍន៍ ការប្រមូលផ្តុំគណនីធនាគារ ព័ត៌មាននិងឯកសារពាក់ព័ន្ធនឹងការអនុញ្ញាតអាជីវកម្មប្រេង និងឧស្ម័ន ។
- ក្រុមការងារកែទម្រង់របស់ក្រសួង-ស្ថាប័នមួយចំនួន ពុំមានមធ្យោបាយបំពេញការងារគ្រប់គ្រាន់ ការបែងចែកការងាររវាងមន្ត្រីនៃក្រុមការងារពុំបានច្បាស់លាស់នៅឡើយ ហើយក្រុមការងារក៏ពុំមានកញ្ចប់ថវិកាដើម្បីគាំទ្រដល់ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។

## ៤-  សេចក្តីសន្និដ្ឋាន

ជារួមនៅក្នុងត្រីមាសទី ១ (ខែមករា ខែកុម្ភៈ និងខែមីនា) ឆ្នាំ ២០១០ នេះ សកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានវឌ្ឍនភាពទៅមុខជាប្រក្រតី និងត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ពីបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជា ក្រសួង-ស្ថាប័ន។ ការខិតខំប្រឹងប្រែងអនុវត្តសកម្មភាពកំណែទម្រង់ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់តួអង្គនីមួយៗ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ដែលបានរៀបរាប់ពីខាងលើ។ ប៉ុន្តែទោះជាយ៉ាងណាបញ្ហាប្រឈមមួយចំនួនដែលអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នជួបប្រទះ បានបណ្តាលឱ្យគោលដៅមួយចំនួនដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី ២ មិនអាចសម្រេចបានពេញលេញ។ បញ្ហាប្រឈមទាំងនេះ ទាមទារនូវដំណោះស្រាយជាក់លាក់ដើម្បីគាំទ្រដល់ការអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ផ្អែកតាមលទ្ធផលការងារ និងការពិនិត្យបញ្ហាប្រឈមខាងដើម លេខាធិការដ្ឋានកត់សំគាល់ចំណុចមួយចំនួនដែលគួរមានការពិចារណា និងយកចិត្តទុកដាក់:

- ការពិនិត្យឡើងវិញអំពីការបែងចែក និងការកំណត់មុខងារ ភារកិច្ចច្បាស់លាស់របស់មន្ត្រីទទួលបន្ទុកការងារផ្នែកកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- អង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន គួរពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័នដើម្បីឱ្យមានលក្ខណៈជាក់លាក់ និងសង្គតិភាពទៅនឹងផែនការសកម្មភាពរបស់អង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- របបរាយការណ៍ប្រចាំខែអំពីការអនុវត្តសកម្មភាពកំណែទម្រង់នៅក្នុងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ត្រូវបន្តអនុវត្តឱ្យបានទៀងទាត់ ។
- ត្រូវជំរុញ និងរៀបចំផែនការកសាងសមត្ថភាពដ៏មានប្រសិទ្ធភាពរបស់ក្រសួង-ស្ថាប័ននីមួយៗដើម្បីដោះស្រាយបញ្ហាប្រឈមនៃកង្វះធនធានមនុស្ស និងសមត្ថភាពមានកម្រិតរបស់មន្ត្រី ។
- ការចងក្រងលិខិតដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមវិស័យឱ្យបានពេញលេញ និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

---------------------